វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺៈ

- ចំនួនភ្ញៀវទេសចរទៅកាន់ប្រាសាទអង្គរវត្តធ្លាក់ចុះនៅក្នុងត្រីមាសទី១ ចំណូលពីការលក់សំបុត្រធ្លាក់ចុះជិត១០%
- ស្ថានភាពធុរៈកិច្ចនៅប្រទេសថៃមានការរីកចម្រើននៅក្នុងខែមីនា
- ធនាគារអាមេរិកបន្ថែមឥណទានទិញផ្ទះ ចំនួន ៥ប៊ីលានដុល្លារសម្រាប់អ្នកដែលមានប្រាក់ចំណូលទាបនិងមធ្យម

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ចំនួនភ្ញៀវទេសចរទៅកាន់ប្រាសាទអង្គរវត្តបានធ្លាក់ចុះនៅក្នុងត្រីមាសទី១ ឯចំណូលពីការលក់សំបុត្រធ្លាក់ចុះជិត១០%

ចំនួនភ្ញៀវទេសចរបរទេសដែលទៅកាន់ឧទ្យានបុរាណអង្គរ បានធ្លាក់ចុះ ៨,២% នៅក្នុងត្រីមាសទី១នៃឆ្នាំ ២០១៩ បើធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ ហើយចំណូលពីការលក់សំបុត្របានធ្លាក់ចុះ ៩,៣% នេះបើយោងទៅលើសេចក្តីថ្លែងការណ៍ដែលបានចេញផ្សាយដោយ វិទ្យាស្ថានគ្រឹះស្ថានអង្គរនៅដើមសប្តាហ៍នេះ។

លោកស្រី ឆាយ ស៊ីវលីន ប្រធានសមាគមភ្នាក់ងារទេសចរណ៍កម្ពុជា បានចាត់ទុកការធ្លាក់ចុះនេះ ដោយសារកង្វះការផ្សព្វផ្សាយ និងការកើនឡើងនៃតម្លៃសំបុត្រដែលបណ្តាលអោយទេសចរមួយចំនួនទិញសំបុត្រចូលទស្សនារយៈពេលមួយថ្ងៃ ជំនួសសំបុត្ររយៈពេលបីថ្ងៃវិញ។

កាលពីឆ្នាំមុន តម្លៃសំបុត្របានកើនពី ២០ដុល្លារទៅដល់ ៣៧ដុល្លារសម្រាប់សំបុត្រដែលមានរយៈពេលមួយថ្ងៃ ពី ៤០ដុល្លារដល់ ៦២ដុល្លារសម្រាប់សំបុត្របីថ្ងៃ និងពី៦០ ដុល្លារដល់ ៧២ដុល្លារសម្រាប់សំបុត្រចូលទស្សនារយៈពេលមួយសប្តាហ៍។

មូលហេតុនៃការធ្លាក់ចុះនេះក៏អាចមកពីការធ្លាក់ចុះសេដ្ឋកិច្ចសកលលោក និងការកើនឡើងនូវភាពមិនច្បាស់លាស់ផ្នែកហិរញ្ញវត្ថុ នៅក្នុងបណ្តាប្រទេសរបស់ភ្ញៀវទេសចរដែលមកលេងប្រទេសកម្ពុជា ។

### តារាងប្រចាំសប្តាហ៍៖ កំណើនវិនិយោគនៅកម្ពុជា

ការវិនិយោគសរុបនៅកម្ពុជា (ទាំងវិនិយោគក្នុងស្រុក និងពីបរទេស) បានកើនឡើងយ៉ាងខ្លាំង ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។ តារាងសប្តាហ៍នេះ បង្ហាញថា ការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស (SEZ) បានកើនឡើង៥0% ជាមធ្យមប្រចាំឆ្នាំ ខណៈដែលការវិនិយោគផ្សេងទៀតបានកើនឡើង ១៨% ជាមធ្យមប្រចាំឆ្នាំ។

### កំណើនវិនិយោគនៅកម្ពុជា (គិតជាលានដុល្លារ)




ប្រភព៖ ក្រសួងការបរទេស និងសហប្រតិ្តការអន្តរជាតិ

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ធុរកិច្ចនៅប្រទេសថៃមានការរីកចម្រើននៅក្នុងខែមីនា

ស្ថានភាពនៃការយល់ឃើញផ្នែកធុរកិច្ចនៅក្នុងប្រទេសថៃមានការរីកចម្រើននៅក្នុងខែមីនា បើយោងតាមការស្ទង់មតិរបស់ធនាគារថៃដែលបានធ្វើអង្កេតទៅលើ ក្រុមហ៊ុនចំនួន ១៥00។ សន្ទស្សន៍ការយល់ឃើញផ្នែកធុរកិច្ច (BSI) របស់ធនាគារថៃ គឺជាការវាស់វែងពីការរំពឹងទុករបស់សហគ្រិនទៅលើប្រតិបត្តិការផ្សេងៗគ្នាជាច្រើន មានដូចជាការផលិត ចំណាយថ្លៃដើម និងការវិនិយោគ។

សន្ទស្សន៍ការយល់ឃើញផ្នែកធុរកិច្ច (BSI) បានកើនឡើងពី៤៩,៩0ពិន្ទុក្នុងខែកុម្ភៈ ទៅដល់៥១,៤0 នៅក្នុងខែមីនា។

BSI ដែលមានកម្រិតលើស៥0ពិន្ទុ បង្ហាញថា ដំណើរការនៃធុរកិច្ចមានលក្ខណៈល្អប្រសើរ។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### ធនាគាអាមេរិកបានពង្រីកទំហំឥណទាន ៥ប៊ីលានដុល្លារសម្រាប់អ្នកដែលមានប្រាក់ចំណូលទាប និងមធ្យម

ធនាគារអាមេរិក (Bank of America) នឹងផ្តល់ប្រាក់៥ប៊ីលានដុល្លារនៅក្នុងឥណទានទិញផ្ទះ សម្រាប់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប និងមធ្យមនៅសហរដ្ឋអាមេរិកក្នុងរយៈពេលប្រាំឆ្នាំខាងមុខ នៅក្នុងកម្មវិធីមួយដែលហៅថា ដំណោះស្រាយតំបន់ក្បែរខាង (Neighborhood Solutions)។

កម្មវិធីនេះក៏ផ្តល់នូវវិធានការគាំទ្រផ្សេងៗទៀតដែរ ដូចជា ជំនួយសម្រាប់ការបង់រំលស់ និងកម្ចីចំពោះធានារ៉ាប់រង និងកំរៃផ្សេងៗ ដើម្បីជួយដល់អ្នកខ្ចីដែលមានបញ្ហាកង្វះខាតផ្នែកហិរញ្ញវត្ថុ ក្នុងការទិញផ្ទះ។

វិធានការថ្មីៗទាំងនេះគឺធ្វើឡើង បន្ទាប់ពីគំនិតផ្តួចផ្តើមរបស់ធនាគារឯកជនមួយចំនួន ដូចជា J.P Morgan Chase ដើម្បីជួយដល់សហគមន៍ដែលមិនសូវមានការគាំទ្រ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ ទុនបម្រុងអន្តរជាតិរបស់ឥណ្ឌូនេស៊ី ទីក្រុងហុងកុង, ប្រទេសសឹង្ហបុរី និងសមតុល្យពាណិជ្ជកម្មរបស់កោះតៃវ៉ាន់ ប្រទេសហ្វីលីពីន និងប្រទេសចិន។ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការ

ចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយៈ

ថ្ងៃចន្ទ ទី០៨ មេសា ២០១៩

- ទុនបម្រុងអន្តរជាតិ របស់ឥណ្ឌូនេស៊ី សម្រាប់ខែមីនា
- ទុនបម្រុងអន្តរជាតិ របស់ហុងកុង សម្រាប់ខែមីនា
- ទំនុកចិត្តអ្នកប្រើប្រាស់ក្នុងប្រទេសជប៉ុន សម្រាប់ខែមីនា
- គណនីចរន្តរបស់ប្រទេសជប៉ុន សម្រាប់ខែកុម្ភៈ
- សមតុល្យពាណិជ្ជកម្ម របស់កោះតៃវ៉ាន់ សម្រាប់ខែមីនា
- ការរំពឹងទុកអតិផរណារបស់អ្នកប្រើប្រាស់ នៅអាមេរិក សម្រាប់ខែមីនា

ថ្ងៃអង្គារ ទី០៩ មេសា ២០១៩

- ការលក់រាយ នៅឥណ្ឌូនេស៊ី សម្រាប់ខែកុម្ភៈ
- ទុនបម្រុងអន្តរជាតិ របស់សឹង្ហបុរី សម្រាប់ខែមីនា
- អត្រាអតិផរណារបស់កោះតៃវ៉ាន់ សម្រាប់ខែមីនា

ថ្ងៃពុធ ទី១០ មេសា ២០១៩

- អត្រាអ្នកអត់ការងារធ្វើនៅកូរ៉េខាងត្បូង សម្រាប់ខែមីនា
- កម្ចីធនាគាររបស់ប្រទេសជប៉ុន សម្រាប់ខែមីនា
- ការវិនិយោគដោយផ្ទាល់ពីបរទេស របស់ប្រទេសហ្វីលីពីន សម្រាប់ខែមករា
- អត្រាអតិផរណា របស់អាមេរិក សម្រាប់ខែមីនា

ថ្ងៃព្រហស្បតិ៍ ទី១១ មេសា ២០១៩

- អត្រាអតិផរណា របស់ចិន សម្រាប់ខែមីនា
- សមតុល្យពាណិជ្ជកម្ម របស់ហ្វីលីពីន សម្រាប់ខែកុម្ភៈ
- ផលិតកម្មឧស្សាហកម្ម របស់ម៉ាឡេស៊ី សម្រាប់ខែកុម្ភៈ
- ការវិនិយោគមូលបត្រជប៉ុនដោយបរទេស នៅថ្ងៃទី០៦ ខែមេសា

ថ្ងៃសុក្រ ទី១២ មេសា ២០១៩

- អត្រាអ្នកអត់ការងារធ្វើនៅម៉ាឡេស៊ី សម្រាប់ខែកុម្ភៈ
- ការលក់រាយនៅម៉ាឡេស៊ី សម្រាប់ខែកុម្ភៈ
- អត្រាកំណើនផសស របស់សឹង្ហបុរី
- សមតុល្យពាណិជ្ជកម្ម របស់ចិន សម្រាប់ខែមីនា
- តម្លៃនាំចេញ នាំចូលរបស់កូរ៉េខាងត្បូង សម្រាប់ខែមីនា